00600545

លេខ/No: D390/1/2/2

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**<u>ព័ត៌មានពិស្តារនៃការដាក់ឯកសារ</u>**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ៧១) |
| ដាក់ទៅ | : | អង្គបុរេជំនុំជម្រះ |
| ថ្ងៃដាក់ | : | ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១០ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារដែលបានទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 08 / 09 / 2010
ម៉ោង (Time/Heure): 13:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយ~~ការិ.សហចៅក្រមស៊ើបអង្កេត~~(អបជ): សាធារណៈ / Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 09 / 09 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍ជាបន្ទាន់របស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស បដិសេធមិនទទួលយកចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ និងសំណើសុំផ្អាកដំណើរការនីតិវិធី**

---

**<u>អ្នកដាក់ឯកសារ:</u>**
សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**<u>អ្នកទទួលឯកសារ:</u>**
អង្គបុរេជំនុំជម្រះ:
ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម ន័យ ធុល
ចៅក្រម ហ្វូត រុទ្ធី

**ជនត្រូវចោទ និង ក្រុមមេធាវី:**
នួន ជា
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor KOPPE

អៀង សារី
លោក អាង ឧត្តម
លោក Michael G.KARNAVAS

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី:**
លោក គីម ម៉េងឃី
កញ្ញា ម៉ុច សុវណ្ណារី
លោកស្រី Martine JACQUIN
លោក Philippe CANNONE
លោកស្រី Elizabeth RABESSANDRATANA
លោកស្រី Annie DELAHAIE
លោកស្រី Fabienne TRUSSES-NAPROUS
លោក នី ចាន់ឌី

00600546



ចៅក្រម Catherine MARCHI-UHEL
ចៅក្រម Rowan DOWNING

**អៀង ធីរិទ្ធ**
លោក ផាត់ ពៅស៊ាង
កញ្ញា Diana ELLIS

**ខៀវ សំផន**
លោក សរ សូវាន
លោក Jacques VERGES

**កាំង ហ្គេកអ៊ាវ *ហៅ* ឌុច**
លោក ការ សាវុត្ថ
លោក កង ឫទ្ធារី

លោក ឡូ ជុនធី
កញ្ញា SILKE Studzinsky
លោក គង់ ពិសី
លោក ហុង គីមសួន
លោក យុង ផានិត
លោកស្រី ស៊ីន សុវ៉ន
លោក Mahdev MOHAN
លោកស្រី NGUYEN Lyma
កញ្ញា Marie GUIRAUD
លោក Patrick BAUDOUIN
លោក Olivier BAHOUGNE

## ១. សេចក្តីផ្តើម

១. វិធានផ្ទៃក្នុង ("វិធាន") ចែងគ្មានសល់នូវបញ្ជីអំពីដីកា និងសេចក្តីសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតដែលអាចប្តឹងឧទ្ធរណ៍បាន ទៅអង្គបុរេជំនុំជម្រះដោយជនត្រូវចោទ។ ដីកាសម្រេចផ្សេងៗទៀតរបស់សហចៅក្រមស៊ើបអង្កេត ត្រូវស្ថិតក្រោមការគ្រប់គ្រងតាមរយៈមោឃភាពនៃនីតិវិធី។ សេចក្តីជូនដំណឹងអំពីការដាក់ឯកសារ មិនគ្រប់គ្រាន់ធ្វើឡើងដោយក្រឡាបញ្ជី មិនមែនជា "ដីកា ឬសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត"ទេ និងថាហេតុដូច្នេះ មិនអាចប្តឹងឧទ្ធរណ៍បានឡើយ ។

២. វិធានបង្កើតនូវប្រព័ន្ធនីតិវិធី *ពិសេស* មួយ សម្រាប់តុលាការនេះ ដោយឈរលើកាលៈទេសៈប្លែកពិសេសរបស់តុលាការនេះ។ ហេតុដូចនេះ វិធានទាំងឡាយរួមបង្កើតបានជាឧបករណ៍ចំបងដែលសេចក្តីយោងនានា គួរតែត្រូវបានគេធ្វើឡើង នៅក្នុងការកំណត់អំពីនីតិវិធី នៅចំពោះមុខតុលាការនេះ[1]។ វិធានមិនបានផ្តល់ឱកាសផ្សេងណាមួយដល់ជនត្រូវចោទ ដើម្បីធ្វើចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាទេ។ ដីកាសន្និដ្ឋានស្ថាពរ ដូចគ្នានឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមដែរ សុទ្ធតែត្រូវបានដាក់ដោយសហព្រះរាជអាជ្ញា នៅក្នុងការអនុវត្តតួនាទីដ៏ប្លែកពិសេសរបស់ខ្លួន ក្នុងការធ្វើជាតំណាងឱ្យ "ផលប្រយោជន៍យុត្តិធម៌" និងក្នុងការផ្តើមចោទប្រកាន់ព្រហ្មទណ្ឌ "ក្នុងផលប្រយោជន៍ទូទៅរបស់សាធារណជន"[2] ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម គឺជាអនុសាសន៍កំណត់ពីបរិបទខាងអង្គហេតុនៃកិច្ចស៊ើបសួរ ហើយដីកាសន្និដ្ឋានស្ថាពរ មានផ្ទុកអនុសាសន៍ទាំងឡាយដែលមិនចងកាតព្វកិច្ចចំពោះសហចៅក្រមស៊ើបអង្កេតទេ[3]។ ឯកសារទាំង

[1] សាលដីកាលើបណ្តឹងឧទ្ធរណ៍តរបស់ នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព, បណ្តឹងឧទ្ធរណ៍លេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ០៦), ចុះថ្ងៃទី២៦ សីហា ២០០៨, ឯកសារលេខ: D55/I/8, កថាខ័ណ្ឌទី ១៤ ។

[2] សេចក្តីសម្រេចលើសំណើរួមរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំឱ្យចេញសេចក្តីសម្រេចលើសិទ្ធិរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការធ្វើសេចក្តីសន្និដ្ឋានអំពីការផ្តន្ទាទោស និងសេចក្តីបង្គាប់ទាក់ទិននឹងការចម្លើយជនជាប់ចោទ, អ្នកជំនាញ និងសាក្សី ក្នុងការធ្វើសក្ខីកម្មអំពីអត្តចរិត, សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អវតក/អជសដ, ចុះថ្ងៃទី៩ តុលា ២០០៩, ឯកសារលេខ: D72/3, កថាខ័ណ្ឌទី ២០ ។

[3] វិធានផ្ទៃក្នុង, ច្បាប់វិសោធនកម្មលើកទី៥, ចុះថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១០ ("វិធាន"), វិធាន ៥៥.២, វិធាន ៦៧.១ នៃវិធានផ្ទៃក្នុង ។

នេះ ជាឯកសារពិសេសប្លែកពីគេចំពោះតួនាទីរបស់សហព្រះរាជអាជ្ញា និងថាបើដូច្នេះមិនអនុញ្ញាតឱ្យមានចម្លើយតបពីគូភាគីផ្សេងឡើយ ។

៣. សិទ្ធិទទួលបានសវនាការដោយត្រឹមត្រូវយុត្តិធម៌របស់ជនត្រូវចោទ មិនមែនត្រូវបានរំលោភដោយគ្រាន់តែអវត្តមាននៃបទប្បញ្ញត្តិមួយ សម្រាប់ធ្វើចម្លើយតបណាមួយទៅនឹងដីកាសន្និដ្ឋានស្ថាពរទេ ដោយហេតុថា ជនត្រូវចោទមានលទ្ធភាពគ្រប់បែបយ៉ាង ដើម្បីដាក់សារណារបស់ខ្លួនអំពីអង្គហេតុ អង្គច្បាប់ និងសំណើផ្សេងៗសុំបំពេញកិច្ចស៊ើបសួរនៅក្នុងអម្លុងពេលនៃកិច្ចស៊ើបសួរ ហើយពួកគេក៏បានពឹងផ្អែកទៅលើមោឃភាព និងបទប្បញ្ញត្តិអំពីការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសកម្មភាពនានារបស់សហចៅក្រមស៊ើបអង្កេត។ ជាការបន្ថែម សហចៅក្រមស៊ើបអង្កេត មិនជាប់កាតព្វកិច្ចទៅតាមការកំណត់បទចោទរបស់សហព្រះរាជអាជ្ញា និងអង្គជំនុំជម្រះសាលាដំបូងទេ ហើយផ្ទុយមកវិញ ក៏មិនជាប់កាតព្វកិច្ចទៅតាមការកំណត់បទចោទនៅក្នុងដីកាដំណោះស្រាយដែរ។ ហេតុដូចនេះ ប្រសិនបើត្រូវចោទប្រកាន់ ជនជាប់ចោទនឹងមានឱកាសតវ៉ានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងអំពីខ្លឹមសារនៃដីកាដំណោះស្រាយ។

៤. វិធានក៏មិនបានផ្តល់ឱ្យមានការផ្អាកកិច្ចស៊ើបសួរដោយអង្គបុរេជំនុំជម្រះដែរ។ ទម្រង់នីតិវិធីប្លែកពិសេសនៃវិធានទាំងនេះ ដូចជាអវត្តមាននៃលក្ខខណ្ឌតម្រូវសម្រាប់ការដាក់ចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរនេះ ដែលបានបង្កើតឡើងដោយកិច្ចប្រជុំពេញអង្គរបស់តុលាការ មិនអាចផ្តល់ជាទឡ្ហីករណ៍សម្រាប់ផ្អាកដំណើរការនីតិវិធីទេ តាមអ្វីដូចដែលមេធាវីការពារក្តីបានស្វែងរកនោះ។ ទោះក្នុងករណីណាក៏ដោយ មិនស្មើនឹងការរំលោភបំពានកិច្ចដំណើរការនីតិវិធី ដើម្បីបង្ខំឱ្យអង្គបុរេជំនុំជម្រះលែងទទួលស្គាល់យុត្តាធិការរបស់ខ្លួន និងផ្អាកដំណើរការនីតិវិធីនោះ។ អាស្រ័យហេតុដូចនេះ បណ្តឹងឧទ្ធរណ៍គួរតែត្រូវបានបដិចោលដោយសារហេតុថា តាមនីតិវិធី មិនអាចទទួលយកបាន និងគ្មានអង្គសេចក្តីជាសារធាតុ[4]។

## ២. បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី គឺមិនអាចទទួលយកបានទេ

[4] បណ្តឹងឧទ្ធរណ៍ជាបន្ទាន់របស់ អៀង សារី ប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស បដិសេធមិនទទួលយកការដាក់ចម្លើយតបរបស់ អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ និងសេចក្តីសង្កេតបន្ថែម និងសំណើរបស់សុំផ្អាកដំណើរការនីតិវិធី, ចុះថ្ងៃទី៦ កញ្ញា ២០១០ ("បណ្តឹងឧទ្ធរណ៍") ។

៥. វិធានចែងពីដីកា និងសេចក្តីសម្រេចមួយចំនួនរបស់សហចៅក្រមស៊ើបអង្កេត ដែលជនត្រូវចោទអាចប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះបាន[5]។ បញ្ជីនោះទូលំទូលាយណាស់ ហើយអង្គបុរេជំនុំជម្រះ មានយុត្តាធិការសម្រេចលើបណ្តឹងឧទ្ធរណ៍ណាដែលជំទាស់ទៅនឹងដីកា និងសេចក្តីសម្រេចដែលមានរៀបរាប់រួចហើយតែប៉ុណ្ណោះ[6]។ ដីកាសម្រេចផ្សេងៗទៀតរបស់សហចៅក្រមស៊ើបអង្កេត ត្រូវឋិតនៅក្រោមការត្រួតពិនិត្យតាមរយៈមោឃភាពនីតិវិធី ដែលធានាថាជនត្រូវចោទណាក៏ដោយ អាចនឹងលើកសំណើថា ដំណើរការនីតិវិធីត្រូវបានប៉ះពាល់ដោយសារវិការៈខាងនីតិវិធីដែលរំលោភលើសិទ្ធិរបស់គាត់ គឺត្រូវទុកជាមោឃៈ[7]។ ការជូនដំណឹងស្តីពីការខ្វះខាតនៅក្នុងការដាក់ឯកសារពីសំណាក់ក្រឡាបញ្ជីនៃសហចៅក្រមស៊ើបអង្កេត គឺពុំមែនជា"ដីកា ឬសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតនោះឡើយ"។ ដូច្នេះហើយ គឺពុំអាចប្តឹងឧទ្ធរណ៍បានទេ។

៦. តាមរយៈសកម្មភាពដែលអាចចោទសួរបាននេះ ក្រឡាបញ្ជីពុំដែលបានធ្វើដីកា ឬសេចក្តីសម្រេចណាមួយឡើយ។ ក្រឡាបញ្ជីគ្រាន់តែបាន "បង្វិលត្រឡប់ទៅវិញ" នូវការដាក់ឯកសារមួយដែលមាន ការខ្វះខាតដើម្បីធ្វើការកែតម្រូវឡើងវិញ ដែលអាចនឹងត្រូវបានដាក់ជាខាងក្រោយនូវឯកសារមួយ ដែលមានទម្រង់របស់វាដ៏ត្រឹមត្រូវ[8]។ ការដាក់ឯកសារនោះ គឺមិនអាចអនុញ្ញាតឱ្យបាននិងមានការខ្វះខាត។ វាជាឯកសារមួយដែលមានចំនួនហុកសិបប្រាំមួយ(៦៦)ទំព័រ (ច្រើនក្រាស់ក្រែលជាងចំនួនដប់ប្រាំ(១៥)ទំព័រ ដែលសេចក្តីណែនាំអនុវត្តបានអនុញ្ញាត[9]) ហើយវាត្រូវបានដាក់ ថ្វីបើមានដីកាបដិសេធមួយរបស់សហចៅក្រមស៊ើបអង្កេតឱ្យទទួលយកក៏ដោយ។ វាជាការណ៍មួយដែលគួរឱ្យកត់សម្គាល់ថា ជនត្រូវចោទពុំបានជ្រើសរើសធ្វើការប្តឹងឧទ្ធរណ៍លើ

---

[5] វិធាន ៧៣, វិធាន ៧៤.៣ ។

[6] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ កសចស ស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ, បណ្តឹងឧទ្ធរណ៍លេខ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ-១២), ថ្ងៃទី២០ កុម្ភៈ ២០០៩, A190/II/9 ("សាលដីកាស្តីពីសិទ្ធិទាក់ទងនឹងការបកប្រែ"), កថាខណ្ឌទី ២៨ ។

[7] សាលដីកាស្តីពីសិទ្ធិទាក់ទងនឹងការបកប្រែ, កថាខណ្ឌទី ២៨ ។ វិធាន ៧៦ ។

[8] សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អវតក, វិសោធនកម្មទី ៤, ថ្ងៃទី៥ មិថុនា ២០០៩ ("សេចក្តីណែនាំអនុវត្ត"), មាត្រា ១០.២ ។

[9] សេចក្តីណែនាំអនុវត្ត, មាត្រា ៥.១ ។

ដីកាបដិសេធ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១០ នោះទេ[10]។ អាស្រ័យហេតុដូច្នេះ ការប្រាស្រ័យទាក់ទងរបស់ក្រឡាបញ្ជី គឺពុំមែនជាដីកា ឬជាសេចក្ដីសម្រេចមួយដែលអាចរកភស្តុតាងប្ដឹងឧទ្ធរណ៍បាននៅចំពោះមុខអង្គបុរេជំនុំជម្រះទេ។ អាស្រ័យហេតុដូច្នេះ បណ្ដឹងឧទ្ធរណ៍នេះគួរតែត្រូវបានបដិសេធចោល ពីព្រោះនីតិវិធីបានរាំង។

## ៣. មេធាវីការពារក្ដីមិនមានសិទ្ធិដាក់ចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរទេ

៧. ច្បាប់ និងវិធានសម្រាប់ អវតក ពុំមានចែងបញ្ញត្តិណាមួយសម្រាប់ឱ្យមេធាវីការពារក្ដីធ្វើការដាក់ចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាទេ។ វិធាន ៦៦ និង ៦៧ បង្កើតជានីតិវិធិដែលនៅចុងបញ្ចប់នៃការស៊ើបសួរ គេតម្រូវឱ្យសហព្រះរាជអាជ្ញាដាក់ដីកាសន្និដ្ឋានស្ថាពរមួយ ហើយបន្ទាប់ពីនោះសហចៅក្រមស៊ើបអង្កេតចេញដីកាដំណោះស្រាយរបស់ខ្លួន ដោយឯករាជ្យ គឺមិនជាប់កាតព្វកិច្ចធ្វើតាមដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាទេ។ ចរិតលក្ខណៈលំអិតនៃសិទ្ធិ និងកាតព្វកិច្ចរបស់សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត គឺមាននៅក្នុងវិធានទាំងនេះ ដែលផ្ទុយទៅនឹងអវត្តមាននៃសិទ្ធិ ឬកាតព្វកិច្ចរបស់ជនត្រូវចោទដែលត្រូវនឹងសិទ្ធិ និងកាតព្វកិច្ចនេះនៅត្រង់បញ្ហាដូចគ្នា នោះវាបញ្ជាក់បានថា មេធាវីការពារក្ដីពុំមានសិទ្ធិធ្វើការឆ្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរទេ។ ការពិតដែលថា វិធានទាំងនេះបានផ្ដល់សិទ្ធិយ៉ាងជាក់ច្បាស់ដល់មេធាវីការពារក្ដីឱ្យបានចូលរួមនៅក្នុងការស៊ើបសួរ តាមវិធាន ៥៥.១០ និងប្ដឹងឧទ្ធរណ៍លើដីកា និងសេចក្ដីសម្រេចនានា នៅក្រោមកាលៈទេសៈជាក់ស្ដែងតាមវិធាន ៧៤ និងផ្ទុយ ពីអវត្តមានរបស់ខ្លួន តាមវិធាន ៦៦ និង ៦៧ បានបង្ហាញថាក្រុមអ្នកព្រាង (ច្បាប់ និង វិធាន) មានគោលបំណងនៅក្នុងការមិនផ្ដល់សិទ្ធិឱ្យដល់មេធាវីការពារក្ដី នៅក្នុងការឆ្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរនោះទេ។

៨. បន្ថែមលើនេះ សេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារនៅចំពោះមុខ អវតក បានអនុញ្ញាតតាមវិធាន ២០ ឱ្យមានសិទ្ធិរបស់ជនត្រូវចោទខុសគ្នា នៅក្នុងការដាក់ចម្លើយតបទៅនឹងសារណានានា

---

[10] លិខិតរបស់សហចៅក្រមស៊ើបអង្កេត ផ្ញើជូនទៅក្រុមមេធាវីការពារក្ដីលោក អៀង សារី, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស, ថ្ងៃទី១៩ សីហា ២០១០, A390/I/I ("ដីកាសម្រេចបដិសេធ") ។

និងការអនុវត្តដោយផ្តល់ជាពេលវេលា[11] និងចំនួនទំព័រកំណត់[12] សម្រាប់ការដាក់ឯកសារបែបទាំងនោះដែលផ្ទុយពីអវត្តមាននៃសិទ្ធិរបស់ខ្លួន នៅក្នុងការឆ្លើយតបទៅនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម និងដីកាសន្និដ្ឋានស្ថាពរ។ សេចក្តីណែនាំអនុវត្ត ពុំបានទទួលស្គាល់ពីសិទ្ធិនោះទេ ឬក៏ពីពេលវេលា ឬចំនួនទំព័រកំណត់ថាត្រូវធ្វើដូច្នោះនោះក៏ទេដែរ[13]។ ជាផលវិបាក សេចក្តីណែនាំអនុវត្ត គឺមានភាពរលូនទៅនឹងវិធាន នៅក្នុងន័យដែលថាទាំងពីរនេះ បានសម្រេចថា ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម និងដីកាសន្និដ្ឋានស្ថាពរ គឺដាច់ផ្សេងពីគ្នា និងឯករាជពីសារណា និងការអនុវត្តដទៃទៀតដោយមានសិទ្ធិ និងកាតព្វកិច្ចនេះខុសគ្នា។

## ៤. សិទ្ធិមេធាវីការពារក្តីក្នុងការទទួលបាននូវសវនាការជំនុំជម្រះក្តីដោយត្រឹមត្រូវ យុត្តិធម៌ត្រូវបានការពារ

៩. ក្រៅពីវិធានផ្ទៃក្នុង និងសេចក្តីណែនាំអនុវត្តដែលមិនប្រគល់សិទ្ធិទៅឱ្យមេធាវីការពារក្តីដើម្បីធ្វើការឆ្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរនោះ ផ្ទុយពីការអះអាងរបស់មេធាវីការពារក្តី សកម្មភាពរបស់ក្រឡាបញ្ជីនៃសហចៅក្រមស៊ើបអង្កេតដែលបដិសេធមិនឱ្យជនត្រូវចោទធ្វើការឆ្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរ គឺមិនបានបំពានទៅលើសិទ្ធិរបស់ជនត្រូវចោទ ក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌នោះឡើយ។ និយាយឱ្យខ្លី សិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយត្រឹមត្រូវ យុត្តិធម៌ គឺមិនបានកំណត់អាណត្តិថាភាគីនីមួយៗសុទ្ធតែមានសិទ្ធិដូចគ្នាបេះបិទនៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការនីតិវិធីនោះឡើយ ជាពិសេសនៅទីនេះ ដែលមានតែសហព្រះរាជអាជ្ញាប៉ុណ្ណោះដែលមានតួនាទីពិសេសតែមួយគត់នៅក្នុងដំណាក់កាលមុនសវនាការជំនុំជម្រះ។

១០. យុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ ឆ្លុះបញ្ចាំងឱ្យឃើញពីសញ្ញាណថា វិធាន២១ នៃវិធានផ្ទៃក្នុងដែលចែងថា "ត្រូវតែយុត្តិធម៌ និងគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ" នោះ គឺមិនតម្រូវថាឱ្យគ្រប់ភាគីទាំងអស់ត្រូវតែបានប្រព្រឹត្តដូចគ្នា

[11] សេចក្តីណែនាំអនុវត្ត, មាត្រា ៨ ។

[12] សេចក្តីណែនាំអនុវត្ត, មាត្រា ៥.១ ។

[13] សេចក្តីណែនាំអនុវត្ត, មាត្រា ៥.៥ ។

ទាំងស្រុងនៅគ្រប់ពេលវេលាទាំងអស់នោះទេ។ ឧទាហរណ៍ដូចជា អង្គបុរេជំនុំជម្រះបានសម្រេចថា សិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌ គឺមិនរួមបញ្ចូលនូវការបកប្រែសំណុំរឿងទាំងមូលទេ[14]។ ស្រដៀងគ្នានេះ នៅក្នុងដីកាសម្រេចមួយថ្មីៗនេះ អង្គបុរេជំនុំជម្រះបានបដិសេធមិនព្រមទទួលយកនូវបណ្តឹងឧទ្ធរណ៍មួយ ដែលជំទាស់ទៅនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដែលបានច្រានចោលនូវសំណើរបស់មេធាវីការពារក្តី ដែលសុំឱ្យកំណត់អត្តសញ្ញាណ និងពិនិត្យផ្ទៀងផ្ទាត់អំពីខ្សែរយៈនៃការថែរក្សាឯកសារ និងឱ្យបញ្ជាក់ពីយថាភូតឯកសារនិមួយៗ ដែលស្ថិតនៅក្នុងឯកសារដោយឡែកណាមួយ[15]។ ក្នុងការកំណត់ថា ការបដិសេធមិនព្រមទទួលយកបណ្តឹងឧទ្ធរណ៍ នឹងមិនមានការបំពានទៅលើសិទ្ធិរបស់មេធាវីការពារក្តី ក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌ទេនោះ អង្គបុរេជំនុំជម្រះបានគិតគូរយកចិត្តទុកដាក់ទៅលើប្រការដែលថា ការបដិសេធបណ្តឹងឧទ្ធរណ៍ គឺមិនមែនមិនអនុញ្ញាតឱ្យជនត្រូវចោទមានឧបាស្រ័យក្នុងការអភិវឌ្ឍន៍ និងការពាររឿងក្តីរបស់ខ្លួននោះឡើយ[16]។ ការបកស្រាយដ៏ទូលំទូលាយត្រូវបានផ្តល់ជូន ដោយផ្អែកលើវិធាន៧៤.៣ នៃវិធានផ្ទៃក្នុងដែលមិនមានឧបាស្រ័យណាមួយបន្ថែមពីនេះទៀតដើម្បីដោះស្រាយចំពោះសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ដែលត្រូវរងការប៉ះពាល់ទេ[17]។ ក៏ប៉ុន្តែ ក្នុងករណីនេះ គ្មានការអនុវត្តឆន្ទានុសិទ្ធិ ដើម្បីអនុញ្ញាតឱ្យប្តឹងឧទ្ធរណ៍ណាដែលត្រូវបានអនុញ្ញាតឱ្យនោះទេ ពីព្រោះដោយសារជនត្រូវចោទមានឧបាស្រ័យហើយ ។

១១. ការពិនិត្យមើលមួយទៅលើប្រព័ន្ធនៃនីតិវិធីរបស់ អវតក ការទាក់ទងនឹងនីតិវិធីជារួមទាំងមូលបង្ហាញឱ្យឃើញថាអវត្តមាននៃសិទ្ធិមួយរបស់មេធាវីការពារក្តីក្នុងការឆ្លើយតបទៅនឹងដីកាសន្និដ្ឋាន

[14] សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគី ក្នុងការបកប្រែ ចុះថ្ងៃទី ២០កុម្ភៈ ២០០៩, A190II120, កថាខណ្ឌទី ៣៤-៥០ ។

[15] សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់ កសចស របស់ នួន ជា លើកទីដប់ប្រាំមួយ (D253) និង ដប់ប្រាំពីរ (D265) ស្តីពីសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី៦ មេសា ២០១០, កថាខណ្ឌទី ១១។

[16] *ដូចខាងលើ* (ដែលថ្លែងថា "បន្ទាប់ពីការចេញដីកាដំណោះស្រាយ ដែលត្រូវបញ្ជូនដើមបណ្តឹងឧទ្ធរណ៍ទៅជំនុំជម្រះ ហើយផ្អែកលើឯកសារនេះ គាត់អាចធ្វើការជំទាស់អំពីយថាភូតនៃឯកសារដែលមានបញ្ហានេះបាននៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង") ។

[17] *សូមអាន ឧទាហរណ៍ដូចជា* សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់ កសចស របស់ នួន ជា លើកទីដប់ប្រាំបី ស្តីពីសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី១០ មិថុនា ២០១០, កថាខណ្ឌទី ១០-១១ (ដែលអនុម័តយកនូវការបកស្រាយដ៏ទូលំទូលាយអំពីសិទ្ធិរបស់ជនជាប់ចោទក្នុងការប្តឹងឧទ្ធរណ៍ បើសិនជាបញ្ហាទាក់ទងទៅនឹងការចោទប្រកាន់អំពីការខកខានក្នុងការដាក់បញ្ចូលនូវ ភស្តុតាងដោះបន្ទុកនៅក្នុងសំណុំរឿង ។ អង្គបុរេជំនុំជម្រះកំណត់ថា ការចោទប្រកាន់នេះបើសិនជាមានការបង្ហាញភស្តុតាងនោះ អាចនឹងមានផលវិបាកធ្ងន់ធ្ងរទៅលើសិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌") ។

ស្ថាពរ គឺមិនបំពានទៅលើគោលការណ៍ស្តីពីសិទ្ធិស្មើភាពគ្នា ឬសិទ្ធិរបស់ជនត្រូវចោទ "ក្នុងការកសាងឯកសារ និងដូចនេះ ត្រៀមរៀបចំដើម្បីការពារក្តី"[18]។ តាមពិតវិធានផ្ទៃក្នុងបានចែងអំពីឱកាសដ៏សំខាន់សម្រាប់មេធាវីការពារក្តីក្នុងការប្រឆាំងនឹងសេចក្តីសន្និដ្ឋានផ្នែកអង្គហេតុ និងអង្គច្បាប់ដែលបានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ក្រោយពេលដែលដីកាដំណោះស្រាយត្រូវបានចេញ និងនៅក្នុងទូទាំងសវនាការជំនុំជម្រះក្តីទាំងមូល[19]។ តាមការពិត ប្រការដែលមិនមានបញ្ញត្តិជាក់លាក់ដែលចែងពីមេធាវីការពារក្តី ធ្វើការឆ្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរ រហូតទល់នឹងពេលចេញដីកាដំណោះស្រាយនោះ គឺធ្វើឱ្យមានការយល់ដឹងបានយ៉ាងល្អអំពីច្បាប់ទាក់ទងទៅនឹងប្រការដែលថា ដីកាសន្និដ្ឋានស្ថាពរ គឺជា*អនុសាសន៍* តែមួយគត់ដែលបានធ្វើឡើងដោយសហព្រះរាជអាជ្ញា និងដែលជាបុព្វបទនាំមុខ *សេចក្តីសម្រេច* ណាមួយរបស់សហចៅក្រមស៊ើបអង្កេតដែលអាចប្តឹងឧទ្ធរណ៍បាន[20]។

១២. បទដ្ឋានអន្តរជាតិនៃការវិនិច្ឆ័យសេចក្តីត្រឹមត្រូវ មិនតម្រូវឱ្យភាគីនិមួយៗ ទទួលបានដោយច្បាស់លាស់នូវសិទ្ធិដូចគ្នានោះទេ។ ជាជាងនេះ បទដ្ឋានអន្តរជាតិគ្រាន់តែប្រគល់អាណត្តិថា ភាគីនិមួយៗ ត្រូវទទួលបាននូវឱកាសដ៏*សមស្រប*មួយ ដើម្បីបង្ហាញករណីរបស់ខ្លួនក្នុងលក្ខខ័ណ្ឌដែលមិនដាក់ខ្លួនឯងឱ្យស្ថិតនៅក្រោមការចាញ់ប្រៀបជាដុំកំភួនណាមួយនោះទេ[21]។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា បទដ្ឋាននេះត្រូវអនុវត្ត ដោយពិចារណាឱ្យបានត្រឹមត្រូវ ទៅនឹងរចនាសម្ព័ន្ធទាំងមូល និងយន្តការនីតិវិធីដែលបានព្រៀងឡើងជាពិសេស បង្កើតឡើងនៅក្នុងកិច្ចព្រមព្រៀង, ច្បាប់ និងវិធានផ្ទៃក្នុង ។

១៣. នៅក្នុងសាលាក្តីពិសេសនេះ ការអះអាងអំពីដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដំណើរការមិនមែនខុសប្លែកគ្នានឹងការចេញដីកាដំណោះស្រាយនៅតុលាការនេះទេ គឺត្រូវបានអនុវត្តដោយចៅក្រមតែមួយ

---

[18] *សូមអាន* បណ្តឹងឧទ្ធរណ៍, កថាខណ្ឌទី៣៧ ។

[19] *សូមអាន ឧទាហរណ៍ដូចជា* វិធាន៦៧.៥, ៧៤, និង៨៩ នៃវិធានផ្ទៃក្នុង ។

[20] *សូមអាន* វិធាន៦៦.៥ (ចែងថា: សហព្រះរាជអាជ្ញាអាច*សុំ* ឱ្យសហចៅក្រមស៊ើបអង្កេតធ្វើការចោទប្រកាន់ និងបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ឬលើកលែងការចោទប្រកាន់" ។ (*សង្កត់ធ្ងន់ដោយអក្សរទ្រេត*) ។

[21] សូមមើលវិធាន ២១(៥) (ចាប់ពី "សហព្រះរាជអាជ្ញា អាចសុំឱ្យសហចៅក្រមស៊ើបអង្កេតធ្វើការចោទប្រកាន់ ឬ បញ្ជូនជនត្រូវចោទនេះទៅជំនុំជម្រះ ឬលើកលែងការចោទប្រកាន់" ) (*គូសសង្កត់បន្ថែម*) ។

រូបដែលធ្វើការពិនិត្យទៅលើតែភស្តុតាង និងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាប៉ុណ្ណោះ[22]។ នៅតុលាការ ICTY និង ICTR មេធាវីការពារក្តីគ្មានតួនាទីក្នុងកិច្ចស៊ើបសួរការបញ្ជាក់អះអាងលើដីកាសន្និដ្ឋាន ឬ ការបញ្ជាក់អះអាងនៅពេលសវនាការទេ[23]។ វិធាននានារបស់តុលាការ ICTY និង ICTR ត្រូវបានសម្រេចស្របតាមសិទ្ធិទទួលបានសវនាការដោយត្រឹមត្រូវយុត្តិធម៌[24]។ នៅក្នុង អវតក ដូចដែលបានពន្យល់នៅក្នុងកថាខណ្ឌទី៧ខាងលើ មេធាវីការពារក្តីបានចូលរួមយ៉ាងពេញទំហឹងនៅក្នុងការស៊ើបអង្កេត និងអាចប្តឹងឧទ្ធរណ៍បាន ទោះបីជាផ្អែកលើហេតុផលដែលមានការកម្រិតប្រឆាំងនឹងដីកាដំណោះស្រាយ[25]។ ចុងក្រោយ នៅក្នុងសវនាការ មេធាវីការពារក្តីមានសិទ្ធិបដិសេធជាបឋមតាមវិធាន៨៩ នៃវិធានផ្ទៃក្នុង, មានសិទ្ធិក្នុងការធ្វើសេចក្តីសន្និដ្ឋានដាក់ជូនអង្គជំនុំជម្រះលើបញ្ហាណាមួយ តាមវិធាន៩២, មានសិទ្ធិក្នុងការឱ្យកោះហៅសាក្សីនានា និងក្នុងការបង្ហាញឯកសារនានា។ មិនអនុញ្ញាតឱ្យមេធាវីការពារក្តី ធ្វើការឆ្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរ ដោយមិនមានការបំពានបែបណាមួយទៅលើសិទ្ធិរបស់ពួកគេ ក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌ឡើយ។

១៤. សេចក្តីស្នើរបស់មេធាវីការពារក្តីថា *ករណីរបស់ Ruiz-Mateos* សំរេចដោយតុលាការអឺរ៉ុប ក្នុងការវិនិច្ឆ័យសេចក្តីស្តីពីសិទ្ធិមនុស្ស ក្នុងបណ្តឹងរដ្ឋប្បវេណី ផ្តល់នូវការគាំទ្រថា អៀង សារី មានសិទ្ធិឆ្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា គឺមិនត្រឹមត្រូវទេ។ ដើមបណ្តឹងឧទ្ធរណ៍ក្នុងករណីនេះ បានចូលរួមក្នុងនីតិវិធីតុលាការខុសស្រឡះពីគ្នាទាំងស្រុង រដ្ឋប្បវេណីជាប្រភេទមួយ ជាលំដាប់នៃសិទ្ធិ និងកាតព្វកិច្ចខុសគ្នា ដែលបានដើរតួតាំងពីដើមទីរហូតដល់ចុងបញ្ចប់។ ក្នុងករណី *Ruiz-Mateos*- តុលាការបានចាត់ថាសិទ្ធិនៃការវិនិច្ឆ័យសេចក្តីដោយត្រឹមត្រូវតម្រូវឱ្យផ្តល់នូវឱកាស ដើម្បីឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានជាលាយលក្ខអក្សររបស់

[22] *សូមអាន* ឧទាហរណ៍ រដ្ឋអាជ្ញា ទល់នឹង Tadic, សាលដីការបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍, IT-94-1-A, ចុះថ្ងៃទី១៥ កក្កដា ឆ្នាំ១៩៩៩, ឯកសារលេខ: D390/1/2/1.1.1, កថាខ័ណ្ឌទី៥៨ ។

[23] *សូមអាន* វិធាន ៤៧ នៃ RPE នៃតុលាការ ICTY និង ICTR ។

[24] *សូមអាន* វិធាន ៣៩ និង៤៧ នៃ RPE នៃតុលាការ ICTY និង ICTR ។

[25] *សូមមើល* Gregory S. Gordon, ដំណើរឆ្ពោះទៅកាន់នីតិវិធីព្រហ្មទណ្ឌអន្តរជាតិ៖ នីតិវិធី Aspirations and Limitations, 45 Colum. J. Transnat"l L. 635, 655 (2007) (ដោយបានលើកឡើងថា "នីតិវិធីបានអនុញ្ញាតដាក់បញ្ចូលទៅក្នុងច្បាប់លក្ខន្តិកៈ ដើម្បីផ្ទះបញ្ជាំងពីអ្វីដែលបានរកឃើញនៅក្នុងមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ដែលជាឯកសារមួយរៀបរាប់ដោយលោកអគ្គលេខា ថាជាបមាណីយដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ ស្តីពីសិទ្ធិនានារបស់ចុងចោទព្រហ្មទណ្ឌ") ។

ព្រះរាជអាជ្ញា[26]។ មានក្រុមហ៊ុនរបស់គ្រួសារមួយដែលជាដើមបណ្ដឹងឧទ្ធរណ៍ត្រូវបានដកហូតដោយក្រឹត្យនីតិបញ្ញត្តិ ដាក់ឱ្យពួកគេលែងមានអ្វីតវ៉ាបាន។ ករណីនេះ គឺផ្ទុយទាំងស្រុងទៅនឹងសិទ្ធិដែលជនត្រូវចោទអាចទទួលបាន ដើម្បីប្រកួតប្រជែងជាមួយនីតិវិធីច្បាប់ និងអង្គហេតុ ពេញមួយរយៈពេលនៃដំណាក់កាលស៊ើបអង្កេត និងសវនាការ។

១៥. ស្រដៀងគ្នានេះដែរ អំណះអំណាងរបស់មេធាវីការពារក្ដីដែលថា សិទ្ធិទទួលបានសវនាការដោយត្រឹមត្រូវយុត្តិធម៌ត្រូវបានគេរំលោភ ដោយសារតែគាត់មិនត្រូវបានគេប្រព្រឹត្តមកលើដោយស្មើភាពនៅចំពោះមុខច្បាប់នោះ គឺជាការយល់ច្រឡំអំពីប្រភេទនៃគោលការណ៍។ សិទ្ធិទទួលបានការប្រព្រឹត្តិមកលើដោយស្មើភាពនៅចំពោះមុខច្បាប់ គឺជាសិទ្ធិជាមូលដ្ឋានដែលបានធានានៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ និង*ច្បាប់ក្នុងស្រុក* របស់សកម្ពុជា។ ប៉ុន្តែ សិទ្ធិទទួលបានការការពារដោយស្មើភាពនៅចំពោះមុខច្បាប់ គឺ *មានន័យ* ត្រឹមតែ ដើម្បីទប់ស្កាត់ការរើសអើងរវាងមនុស្ស និងមនុស្សនៅក្នុងការអនុវត្តន៍ច្បាប់តែប៉ុណ្ណោះ។ គោលការណ៍ស្ដីពីសិទ្ធិស្មើភាពគ្នានៅចំពោះមុខច្បាប់មិនបានរារាំងមិនឱ្យមានការផ្លាស់ប្ដូរនៅក្នុងផ្លូវច្បាប់ និងក៏មិនបានរារាំងមិនឱ្យមានការបកស្រាយច្បាប់តាមធម្មានុរូបដែលកំពង់បន្តដោយចៅក្រមនោះទេ។ ការពិតដែលថា សហចៅក្រមស៊ើបអង្កេត មិនជំទាស់នឹងចម្លើយតបរបស់ កាំង ហ្កេកអ៊ាវ ("ឌុច") ទៅនឹងដីកាសន្និដ្ឋានស្ថាពរក្នុងសំណុំរឿងលេខ០០១ មិនគួរត្រូវបានគេចាត់ទុកថា ជាការរើសអើងប្រឆាំងនឹងជនត្រូវចោទរូបនេះឡើយ ទាក់ទិននឹងសំណុំរឿងលេខ០០២ ប៉ុន្តែត្រូវចាត់ទុកថា ជាការអភិវឌ្ឍន៍ច្បាប់ជាបន្ត។ ទាក់ទិននឹងស្ថានភាពបច្ចុប្បន្នរបស់ច្បាប់ ដូចបានធ្វើឡើងយ៉ាងប៉ិនប្រសប់ដោយសហចៅក្រមស៊ើបអង្កេតនៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន ទាំងក្នុងករណី កាំង ហ្កេកអ៊ាវ និង អៀង សារី គឺបានប្រព្រឹត្តទៅយ៉ាងស្មើភាពគ្នា។

## ៥. ការផ្អាកដំណើរការនីតិវិធីមិនអនុញ្ញាតទេ

[26] បណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងសេចក្ដីសំរេចរបស់ កសចស ដែលបដិសេធមិនទទួលការដាក់បណ្ដឹងឆ្លើយតប របស់ អៀង សារី ទៅនឹងវិធាន ៦៦ នៃសេចក្ដីសន្និដ្ឋានស្ថាពរ របស់សហព្រះរាជអាជ្ញា និងសេចក្ដីផ្ដេតបន្ថែម និងសេចក្ដីស្នើសុំឱ្យផងអាកដំណើរការនីតិវិធី, 002/19-09-2007-ECCC/OCIJ (PTC 71), ថ្ងៃទី ៦ ខែកញ្ញា ឆ្នាំ២០១០, D330/1/2/1, ERN: 00598683-00598696; សូមមើលផងដែរ *Ruiz-Mateos v. Spain*, Eur. Ct H.R., 16 E.H.R.R., សេចក្ដីវិនិច្ឆ័យ ថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៣, ពាក្យបណ្ដឹងលេខ ១២៩៥២/៨៧, កថាខ័ណ្ឌ ៦៣-៦៨ ។

១៦. វិធានផ្ទៃក្នុងមិនអនុញ្ញាតឱ្យមានការផ្អាកនីតិវិធីទេ។ ដោយសារប្រព័ន្ធ *តុលាការពិសេសនេះ* ភាគីនានាពុំមានមធ្យោបាយដែលអាចកែខៃបាន ប្រឆាំងទៅនឹងសកម្មភាពរបស់សហចៅក្រមស៊ើបអង្កេត ក្នុងដំណាក់កាលនៃការស៊ើបអង្កេត និងសវនាការទេ។ សកម្មភាពទាំងនេះរួមមានការប្ដឹងឧទ្ធរណ៍ និងការធ្វើមោឃភាពនៃនីតិវិធី។ វិធានផ្ទៃក្នុងបានចែងយ៉ាងច្បាស់ថា ក្នុងពេលរង់ចាំនីតិវិធីនៃបណ្ដឹងឧទ្ធរណ៍ កិច្ចដំណើរការស៊ើការស៊ើបអង្កេតអាចបន្តធ្វើបាន[27]។ អង្គបុរេជំនុំជម្រះគ្រាន់តែអាចផ្អាកដំណើរការនីតិវិធីបាន បើសិនជាខ្លួនសន្និដ្ឋាន ដោយឈរលើទ្រឹស្ដីនៃរំលោភលើនីតិវិធីប៉ុណ្ណោះ ដែលសិទ្ធិរបស់ជនត្រូវចោទត្រូវបានរំលោភដ៏ធ្ងន់ធ្ងរ[28] ។

១៧. មេធាវីការពារក្ដី បានខកខានមិនបានលើកយោងអំពីករណីយុត្តិសាស្ត្រណាមួយដែលគាំទ្រដល់ការផ្អាកដំណើរការនីតិវិធីទេ[29]។ ការពិត ក៏គ្មាននៅក្នុងករណីនានាដែលបានលើកយោងដោយមេធាវីការពារក្ដីដែលតុលាការពិតជាធ្លាប់បានផ្អាកដំណើរការនីតិវិធីដែរ[30]។ ការពិតវាអាចពិបាកសម្រាប់ពិចារណាថា ការបដិសេធដោយក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេតនៅលើការដាក់ឯកសាររបស់មេធាវីការពារក្ដី ដោយសារតែវាមានទំហំ៥១ទំព័រ លើសពីចំនួនកំណត់ដែលបានអនុញ្ញាតតាមសេចក្ដីណែនាំអនុវត្ត ដែលជាហេតុនាំឱ្យ*គ្មានលទ្ធភាព* ចំពោះសវនាការដោយត្រឹមត្រូវ

---

[27] វិធាន ៧៧(១) ។

[28] សេចក្ដីសំរេចលើបណ្ដឹងឧទ្ធរណ៍របស់ អៀង ធិរិទ្ធ ប្រឆាំងដីការបស់សហចៅក្រមស៊ើបអង្កេត ដែលបដិសេធការសុំផ្អាកដំណើរការនីតិវិធីដោយឈរលើមូលដ្ឋាននៃការរំលោភលើនីតិវិធី (D264/1), បណ្ដឹងឧទ្ធរណ៍ លេខ 002/19-09-2007-ECCC/OCIJ (PTC 42), ថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០១០, D264/2/6, កថាខ័ណ្ឌ ២៦ ។

[29] *សូមមើល* បណ្ដឹងឧទ្ធរណ៍ជាបន្ទាន់របស់លោក អៀង សារី ប្រឆាំងទៅនឹងសេចក្ដីសម្រេចរបស់ កសចស បដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ និងសេចក្ដីសង្កេតបន្ថែម និងសំណើសុំផ្អាកដំណើរការនីតិវិធី, ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ-៧១), ថ្ងៃទី៦ កញ្ញា ២០១០, D330/1/2/1, ERN 00598683-00598696, កថាខណ្ឌទី ៥ (ដោយបានលើកសំអាងពីសេចក្ដីសម្រេចរបស់ ICTY ចំនួនប្រាំ) ។

[30] *សូមមើល រដ្ឋអាជ្ញា ទល់នឹង Prlic និងគូកន,* IT-04-74-T, សេចក្ដីសម្រេចលើសំណើសុំផ្អាកដំណើរការនីតិវិធីបណ្ដោះអាសន្ន ដាក់ដោយមេធាវីការពារក្ដីរបស់ Praljak, ថ្ងៃទី១៦ មេសា ២០១០, ទំព័រទី ៦ ។ *រដ្ឋអាជ្ញា ទល់នឹង Tadic,* IT-94-I-A, សាលដីកា, ថ្ងៃទី១៥ កក្កដា ១៩៩៩, កថាខណ្ឌទី ៥៥ (ដោយគ្រាន់តែបានលើកឡើងថា តុលាការអាច "យល់ឃើញពីស្ថានភាពនានាដែលការការក្ដីដោយត្រឹមត្រូវពុំអាចមានឡើយ") ។ *រដ្ឋអាជ្ញា ទល់នឹង Nicolic,* IT-94-2-T, សេចក្ដីសម្រេចលើសំណើសុំផ្អាកដំណើរការនីតិវិធីបណ្ដោះអាសន្ន ដាក់ដោយមេធាវីការពារក្ដីរបស់ Praljak, ថ្ងៃទី១៦ មេសា ២០១០, កថាខណ្ឌទី ១០៦-១៥ ។ *រដ្ឋអាជ្ញា ទល់នឹង Bobetko,* IT-02-62-AR54bis, សាលដីកាលើការតវ៉ាពីសំណាក់ ក្រូអាស៊ី ទៅនឹងសេចក្ដីសម្រេច និងដីកានានារបស់ចៅក្រមសម្រេចចុងក្រោយ (Confirming Judges), ថ្ងៃទី២៩ វិច្ឆិកា ២០០២, កថាខណ្ឌទី ១៥ ។ *រដ្ឋអាជ្ញា ទល់នឹង Blagojevic,* IT-02-60-AR73.4, មូលហេតុសាធារណៈ និងដែលត្រូវបានលុបចេញខ្លះៗ សម្រាប់សាលដីកាលើបណ្ដឹងឧទ្ធរណ៍ដាក់ដោយ Vidoje Blagojevic ដើម្បីជំនួសក្រុមមេធាវីការពារក្ដីរបស់គាត់, ថ្ងៃទី៧ វិច្ឆិកា ២០០៣ ។

00600557



យុត្តិធម៌សម្រាប់ជនត្រូវចោទ[31]។ វាពិតជាពិសេសដែលថា ស្ថានភាពបច្ចុប្បន្នមិនគ្រប់គ្រាន់ទាក់ទិននឹងបទដ្ឋានដ៏តឹងរ៉ឹង កំណត់អំពីការផ្អាកដំណើរការនីតិវិធី តាមស្មារតីនៃវិធាននានាដែលមានចែងសម្រាប់មេធាវីការពារក្តី ដើម្បីចូលរួមឲ្យបានពេញលេញនៅក្នុងដំណើរការនៃកិច្ចស៊ើបសួរ និងសវនាការ។ មេធាវីការពារក្តី មិនបានផ្តល់ទឡ្ហីករណ៍ ឬសូម្បីតែការតវ៉ាក៏គ្មាន អំពីការរំលោភដំណើរការ។ បណ្តឹងឧទ្ធរណ៍ ក៏មិនបានស្វែងរកដំណោះស្រាយណាមួយ អំពីការផ្អាកដំណើរការនីតិវិធីនៅក្នុងវាក្យខ័ណ្ឌចុងក្រោយរបស់ខ្លួន ដែលដាក់ចំណងជើងថា "ដំណោះស្រាយដែលស្វែងរក" នោះទេ។ សារណានេះគួរតែត្រូវបានច្រានចោល។

## ៦. ដំណោះស្រាយដែលស្វែងរក

១៨. សហព្រះរាជអាជ្ញា សុំឲ្យអង្គបុរេជំនុំជម្រះ បដិសេធចោលបណ្តឹងឧទ្ធរណ៍នេះ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១០ | **លោក ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក Andrew CAYLEY**<br>សហព្រះរាជអាជ្ញា | | |

[31] *សូមមើល* បណ្តឹងឧទ្ធរណ៍ជាបន្ទាន់របស់មេធាវីការពារក្តី, កថាខណ្ឌទី ៥ ("នៅតុលាការ ICTY យុត្តិសាស្ត្របានបង្កើតឡើងថា ការផ្អាកដំណើរការនីតិវិធី អាចនឹងត្រូវបានដាក់ឲ្យប្រតិបត្តិកាលណាវាពុំអាចមានការកាត់ក្តីដ៏ត្រឹមត្រូវមួយបាន") ។